ព្រឹត្តិបត្រ ប្រចាំខែ

# អ្នកនាំសារ THE MESSENGER

ពត៌មានពីព្រះសហគមន៍កាតូលិក Internal Use ឆ្នាំទី ០២ លេខ ១១ ខែ មីនា ឆ្នាំ ២០០៤

## ក្រុមអេម៉ាណូអែល

"ព្រះជាមាស់គង់ជាមួយយើង"

ជាធម្មតាក្រុមអេម៉ានូអែលគឺ តែងតែជួបជុំគ្នាដើម្បីរិះគិតអំពីបញ្ហាជីវិតរស់នៅរបស់យុវជន។

ដូចដែលបានកំណត់ ក្រុមនេះជួបជុំគ្នាសារជាថ្មីម្តងទៀតនាថ្ងៃសៅរ៍ ទី៧ និងថ្ងៃអាទិត្យ ទី៨ ខែកុម្ភៈ ឆ្នាំ២០០៤ វេលាម៉ោង២រសៀលនៅទេវវិទ្យាល័យ(ទួលគោក-ក្រុងភ្នំពេញ )។ ក្នុងការប្រជុំ គេបានយកប្រធានបទមួយគឺ "ការលើកលែងទោស" មករិះគិត និងប្តូរយោបល់គ្នា។ អង្គប្រជុំមានសមាជិក១៨នាក់គឺៈ យុវជនមាន អាយុពី ១៨-២៣ ឬ ២៥ឆ្នាំ បងស្រី ប៉ោឡា បងស្រី ស៊ីណា ...

តទៅទំព័រទី ២

## ព្រះវិញ្ញាណត្រាស់ហៅខ្ញុំ!

ព្រះសហគមន៍កាតូលិកទូទាំងក្នុងកម្ពុជាសូមកោតសរសើរ និងអបអរសាទរចំពោះការលះបង់ទាំងសាច់ទាំងឈាមនិងឆន្ទៈបួសជាដូនជីរបសបង ស្រីម៉ារីយ៉ា អាង សង្វាត និងបងស្រី ថេរេសា សួន ប៊ុនថារិន ដើម្បីរួមសុខរួមទុក្ខជាមួយគ្រួសារ "បងស្រីស្រឡាញ់ព្រះយេស៊ូលើឈើឆ្កាង" ដែលនឹងប្រារព្ធធ្វើនៅថ្ងៃទី ២១ ខែ មិនា ឆ្នាំ ២០០៤ វេលា ម៉ោង ៩ ព្រឹករនៅព្រះសហគមន៍ភូមិភាគ-កំពង់ចាម។

ក្នុងព្រឹត្តិការណ៍ដ៏អស្ចារ្យនេះ បងស្រីទាំងពីរបានមានប្រសាសន៍ថាៈ បងរំភើប និងអរណាស់ ...

តទៅទំព័រទី ២

# តើអំពើបាបនៅកម្ពុជាជាអ្វី?



លោក ជា វិជ្ជា ប្រធានសហជីព សេរីកម្មករកាលនៅរស់

Khem Sovannara

ព្រឹត្តិការណ៍បាញ់សម្លាប់លោក **ជា វិជ្ជា** ប្រធានសហជីពសេរីកម្មករនៅរាជធានីភ្នំពេញ បានធ្វើឱ្យកម្មករ កម្មការនី មានសេចក្តី សោក-ស្តាយ និងភ័យតក់ស្លុតយ៉ាងក្រៃលេង។ អំពើឃាតកម្មដ៏សាហាវយង់ឃ្នង និងឃោរឃៅនេះកើតឡើងនៅពេលព្រឹក ម៉ោងប្រាំបួនជាងនៅថ្ងៃទី ២២ /០១/២០០៤។ នេះសបញ្ជាក់ឱ្យឃើញថា ឃាតករមិនខ្លាចគេឃើញ និងស្គាល់មុខឬអាជ្ញាធរមានសមត្ថកិច្ចចាប់ខ្លួនទាល់តែសោះ។ ហេតុការណ៍នេះបានធ្វើ ឱ្យប្រជាជននឹកឃើញដល់ឃាតកម្មផ្សេងទៀត ដែលទើបនឹងកើតឡើងនាពេលថ្មីៗកន្លងទៅនេះ ដូចជា ៈ ឃាតកម្មលើម្តាយស្រ្តីអ្នកចំរៀងឈ្មោះ **ទូច ស៊ុននិច** និងលោក **ជួរ ជេតថាឬទ្ធិ** បុគ្គលិកអ្នកយកពត៌មានឱ្យវិទ្យុតាព្រហ្ម-អេហ្វអឹម៩០ (FM.90)។ ទន្ទឹមនឹងរឿងរ៉ាវនេះដែរក៏មានអំពើព្រៃផ្សៃផ្សេងៗទៀតកើតមានឡើងដូចជាៈ ការកាប់សម្លាប់គ្នាដោយជំលោះប្លន់បាញ់សម្លាប់យកមាស លុយ ម៉ូតូ អំពើរំលោភ...

តទៅទំព័រទី ៤

## ព្រះវិញ្ញាណព្រះជាម្ចាស់នៅជាមួយយើង

ហេតុអ្វីក៏យើងយល់ថាៈ ព្រះវិញ្ញាណព្រះជាម្ចាស់នៅជាមួយយើង ? រឿងរ៉ាវនេះបានកើតឡើងជាក់ស្តែងនៅថ្ងៃទី ១២ ខែ កុម្ភៈ ឆ្នាំ ២០០៤ នៅពេលលោអភិបាលព្រះសហគមន៍កំពង់ចាមបានធ្វើដំណើរតាមឡានម៉ាកតូយ៉ូតា(ពីរបាំង)មួយឆ្ពោះ ទៅស្រុកប៊ូស្រា ខេត្តមណ្ឌលគីរី ដើម្បីសួរសុខទុក្ខគ្រិស្តបរិស័ទ ។ អ្នករួមដំណើរមានគ្នាទាំង ...

តទៅទំព័រ ទី ៣

# ពិធីសម្ពោធវិទ្យាល័យសន្តប្រាំងស្វ័រ

កាលពីថ្ងៃទី ២១ ខែកុម្ភៈ ឆ្នាំ ២០០៤កន្លងទៅនេះ នៅព្រះសហគមន៍កាតូលិកចំការទៀងបានធ្វើពិធីសម្ពោធអាគារសិក្សាមួយខ្នងមានពីរជាន់ដែលស្ថិតក្នុងវិទ្យាល័យសន្តប្រាំងស្វ័រ នៅក្នុងភូមិចំការទៀង ឃុំគុស ស្រុកត្រាំកក់ ខេត្ត តាកែវ ។ កម្មវិធីនេះ បានប្រារព្ធឡើងក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តម **ចន្ទ សារុន** រដ្ឋមន្ត្រីក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ និងជាទីប្រឹក្សាផ្ទាល់របស់សម្ដេចនាយករដ្ឋមន្ត្រី **ហ៊ុន សែន** និងលោក**អេមីលដេតម្ប** ជាអភិបាលព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ ព្រមទាំងមានការចូលរួមពីគណៈអធិបតី ភ្ញៀវកិត្តិយសជាតិ និងអន្តរជាតិជាច្រើនរូបទៀត។



*វិទ្យាល័យសន្តប្រាំងស័រ ព្រះសហគមន៍ចំការទៀង (គុយវិន)*

ក្នុងឱកាសនោះ លោកបូជាចារ្យ **អូ លីវីយេ**តំណាងព្រះសហគនមន៏កាតូលិកចំការទៀង បានធ្វើរបាយការណ៏ទាក់ទិនទៅនឹងវិទ្យាល័យសន្តប្រាំងស្វ័រ និងពីមូលហេតុដែលព្រះសហគមន៏សាងសង់អាគារសិក្សានេះឡើង គឺ ដើម្បីជួយសម្រួលដល់គ្រួសារក្រីក្រដែលរស់នៅតំបន់ដាច់ស្រយាលពីទីប្រជុំជន ហើយមានកូនចៅចង់បន្តការសិក្សាឱ្យដល់ថ្នាក់ទី១២ និងចង់បានការងារធ្វើភ្លាម១ដើម្បីជួយលើកស្ទួយជីវភាពគ្រួសារគេ និងជួយដល់សង្គមជាតិផងដែរ។ នៅក្នុងឱកាសនោះផងដែរ លោកឪពុក **អូ លីវីយេ** ក៏បានសំដែងអំណរគុណដ៏ជ្រាលជ្រៅដោយទឹកចិត្តសប្បាយរីករាយចំពោះវត្តមានឯកឧត្តមរដ្ឋមន្ត្រីព្រមទាំងភ្ញៀវជាតិ និងអន្តរជាតិដែលបានចូលរួមក្នុងកម្មវិធីនេះ ហើយដែលញ៉ាំងឱ្យពិធីនេះប្រព្រឹត្តទៅប្រកបដោយមោទនៈភាព និងភាពកក់ក្ដៅជាទីបំផុត ។ឆ្លើយតបមកវិញ ឯកឧត្តមរដ្ឋមន្ត្រីក៏បានសំដែងនូវការពេញចិត្ត និងថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះការជួយជ្រោមជ្រែងឧបត្ថម្ភរបស់គណៈកម្មការព្រះសហគមន៏កាតូលិកចំការទៀងដែលបានផ្ដល់នូវវិភាគទានដ៏ថ្លៃថ្លា ដើម្បីជួយលើកស្ទួយធនធានមនុស្ស និងបំបាត់អនក្ខរភាពតាមជនបទដោយមិនប្រកាន់ពណ៌សម្បុរនិងសាសនាអ្វីឡើយ។ បន្ថែមលើនេះ ឯកឧត្តមបានមានប្រសាសន៏សំណេះសំណាល និងជួយណែនាំប្រជាជនកសិករឱ្យខិតខំធ្វើឱ្យជីវភាពរបស់ខ្លួនបានប្រសើរ ដោយធ្វើទាំងស្រែប្រាំង និងស្រែវស្សា ប្រឹងប្រែងដាំដំណាំ-ចិញ្ចឹមសត្វ ហើយហូបចុកត្រូវប្រយ័ត្នកុំបរិភោគមាន់-ទាដែលមានជំងឺ។



*សិស្សផ្នែកតម្បាញសូត្រ*

Fr. Olivier

កម្មវិធីនេះ បានបញ្ចប់ទៅប្រកបដោយបរិយាកាសសប្បាយរីករាយ និងការប្រកាសឱ្យប្រើប្រាស់ជាផ្លូវការវិទ្យាល័យសន្តប្រាំងស្វ័រដែលជាសមិទ្ធផលសម្រាប់ជួយអ្នកជនបទឱ្យមានទាំងចំណេះដឹងទូទៅ និងជំនាញ (ផ្នែកលេខាធិការ កសិកម្ម តម្បាញសូត្រ កុំព្យូទ័រ និងភាសា) ស្របតាមប្រព័ន្ធក្រសួងអប់រំយុវជន និងកីឡារបស់ប្រទេសកម្ពុជាយើង។

**កុល សៀប**

*តពីទំព័រទី១:*



បងស្រីម៉ារី យ៉ា អាង សង្វាត និង បងស្រី ថេរេសា សួន ប៊ុនថារីន

Fr. Omer

លោកអភិបាលព្រះសហគមន៍ភូមិភាគកំពង់ចាម និងក្រុមគ្រួសារបងស្រីស្រឡាញ់ព្រះយេស៊ូលើឈើឆ្កាងនឹងទទួលបងឱ្យចូលរួមបម្រើព្រះសហគមន៍ដោយផ្ទាល់ក្នុងនាមព្រះយេស៊ូគ្រិស្ត។ បងស្រីក៏បានបញ្ជាក់បន្ថែមថា: វាពុំមែនជាការងាយស្រួលទេក្នុងការ ប្រតិបត្តិតាមព្រះបន្ទូលតាមព្រះយេស៊ូនោះគឺវាប្រៀបដូចជាការធ្វើដំណើរទៅតាមផ្លូវដែលពោរពេញទៅដោយបន្លាយ៉ាងដូច្នេះដែរ។ ប៉ុន្តែអ្វីដែលសំខាន់នោះគឺ នៅក្នុងចិត្តយើងម្នាក់ៗត្រូវតែមានភាពអំណត់អត់ធ្មត់ និងសេចក្តីស្រឡាញ់ដែលព្រះយេស៊ូ បានប្រទានមកឱ្យយើង" ។

បងស្រីបានប្រាប់បន្ថែមទៀតថា: តាមលក្ខន្តិកៈរបស់ក្រុមគ្រួសារបងស្រីស្រឡាញ់ព្រះយេស៊ូលើឈើឆ្កាង មិនមែនមានពិធីធ្វើសច្ចាតែម្តងទេ គឺមានរហូតដល់ទៅ៦ដង ដែលពិធីសច្ចាទី៦នេះជាពិធីសច្ចាអស់មួយជីវិត ហើយនេះទើបតែពិធីសច្ចាលើកទី១ប៉ុណ្ណោះ។ ហើយបន្ទាប់មកទៀត នឹងមានពិធីសច្ចាយូរៗម្តងដើម្បី រំលឹកដល់ពិធីសច្ចាអស់មួយជីវិតរបស់ពួក គាត់ ។

បងស្រីបានដំណាលពីជីវិតជាកូនសិស្សដូនជីអស់រយៈពេល៣ឆ្នាំ បើគិតចាប់តាំងពីថ្ងៃទី ២៩ ខែមិនា ឆ្នាំ ១៩៩៩មក។ បន្ទាប់មក នៅថ្ងៃទី ២ ខែកម្ភៈ ឆ្នាំ២០០២ បងស្រីក៏បានទទួលឱ្យចូលជា "ណូវិស " ដែលមានរយៈពេលមកដល់ ពេលនេះ២ឆ្នាំហើយ ។

ចំពោះកន្លែងបំពេញបេសកកម្មរបស់បងស្រីៗបានរៀបរាប់ថា: ប្រហែលលោកអភិបាលនឹងចាត់ពួកគាត់ ឱ្យទៅរស់នៅជាមួយអ្នកក្រីក្រដើម្បីជួយគេ និងប្រកាសដំណឹងល្អដល់ពួកគេ ព្រមទាំងជួយអ្នកមានទុក្ខលំបាកដោយសារជំងឺព្យាធិ នៅតាមមន្ទីរពេទ្យជួយអប់រំយុវជននៅតាម ព្រះសហគមន៍ដូចជា: ព្រះសហគមន៍អូររាំងឪ និងអ្នកលឿង។ ហើយម្យ៉ាងទៀត បើមានបងប្អូនណាមានបំណងចូលក្រុមរបស់យើងនោះលុះត្រាតែគេសុំការអនុញ្ញាតពីលោកអភិបាលរបស់គេជាមុនសិន ។

ដូច្នេះ សូមបងប្អូនគ្រិស្តបរិស័ទទាំងអស់ជួយអង្វរព្រះជាម្ចាស់សូមព្រះអង្គមេត្តាប្រទានព្រះអំណោយទាន និងព្រះវិញ្ញាណឱ្យដល់បងស្រីក្នុងការប្រកាសផ្សាយដំណឹងល្អរបស់ព្រះជាម្ចាស់និងធ្វើឱ្យព្រះសហគមន៍ចេះតែរីកចំរើនតរៀងទៅ។

សូមឱ្យព្រះជាម្ចាស់ប្រទានឱ្យបងស្រីបំពេញរាល់កិច្ចការប្រកបដោយជោគជ័យជានិច្ច។

***ដាម៉ូ (កំពង់ចាម)***

---

តពីទំព័រទី ១

លោកបូជាចារប៊ុយណូ ហ្វ្រង់កូ ម៉ារីអូ និង អ៊ុន សុន។ លោកឪពុក និងបងស្រីចូលរួមក្នុងនាមជាទីប្រឹក្សាជួយផ្តល់បទពិសោធន៍ឱ្យក្រុម និងដើម្បីជួយលើកទឹកចិត្តក្រុម។

ពាក្យថា "លើកលែងទោស"មានអត្ថន័យយ៉ាងណាខ្លះចំពោះយុវជន ? ពាក្យប៉ុន្មានម៉ាត់នេះ ហាក់បីដូចជាងាយស្រួលយល់ណាស់ ប៉ុន្តែបើពិចារណាឱ្យស៊ីជម្រៅវាពិតជាពិបាកក្នុងការប្រព្រឹត្តខ្លួន។

ដើម្បីជាជំនួយដល់ការគិតពិចារណា លោកឪពុកបានរៀបចំសំនួរមួយចំនួនដូចខាងក្រោម:

-តើ ការលើកលែងទោសមានប្រយោជន៍អ្វីសម្រាប់យុវជន ?

-តើ យើងលើកលែងទោសឱ្យគេគ្រប់កំហុសដែរឬទេ ?

-ហេតុអ្វី ការលើកលែងទោសជាកិច្ចការមួយដ៏ពិបាក ?

-តើ យើងធ្លាប់មានបទពិសោធន៍ពិតប្រាកដក្នុងការលើកលែងទោសដែរឬទេ ?

ក្នុងប្រធានបទខាងលើ បានធ្វើឱ្យពួកគេត្រិះរិះពិចារណា និងបានចែករំលែកបទពិសោធន៍គ្នា។ ជាដំបូងយុវជន ឈ្មោះតឿដែលជាសមាជិកអង្គប្រជុំបាននិយាយថា : លើកកលែងទោសឱ្យអ្នកដទៃ មិនសុទ្ធតែជាការងាយស្រួលទេគឺវាអាស្រ័យទៅលើអំពើប្រព្រឹត្តរបស់អ្នកនោះថាជាទង្វើធន់ឬស្រាល? ហើយ ការលើកលែងទោសវាមានប្រយោជន៍ និងអត្ថន័យ លុះត្រាតែអ្នកនោះចេះទទួល

តពីទំព័រទី ១



*ឡានរបស់លោក អភិបាល អន់តូនី ដែលទទួលរងគ្រោះថ្នាក់ (រូបថត កំពង់ចាម)*

ទាំងអស់១០នាក់ ក្នុងនោះមានលោកអភិបាល លោកបូជាចារ្យ បងស្រី និងគ្រិស្តបរិស័ទផងដែរ។ ឧបទ្ទវហេតុនេះ កើតឡើងនៅពេលធ្វើដំណើរហួសស្រុក កែវសីម៉ា ត្រង់ចំណុចផ្លូវបត់មួយបណ្តាលឱ្យឡានបែកកង់ (កង់ស្តាំខាងក្រោយ) ក្រឡាប់លើផ្លូវជាតិ ។

បើតាមការរាយរ៉ាប់របស់អ្នករួមដំណើរម្នាក់ ឈ្មោះ សុជាតិ ( ស្រី ) បានឱ្យដឹងថា: រថយន្តដែលគ្រោះថ្នាក់នោះគ្មាននរណាម្នាក់របួសធ្ងន់ទេ។ ផ្ទុយទៅវិញ ពួកគេទាំងអស់ស្ទើរតែមិនជឿថា គេរួចពីសេចក្តីស្លាប់ និងគ្រាន់តែរងរបួសបន្តិចបន្តួចតែប៉ុណ្ណោះ។ បងស្រីម្នាក់នេះ បានខំប្រវេប្រវាចេញពីក្នុងឡានដើម្បីរកម៉ាស៊ីនថតមកថតទិដ្ឋភាពគួរឱ្យតក់ស្លុតរបស់ពួកគេក្រោយពីដឹងថាគាត់មានរបួសបន្តិចបន្តួច។

ពួកគេនៅខាងក្រោយ នៅពេលដឹងថាគ្មានរបួសធ្ងន់ទេនោះ គេបានទៅជួយអ្នកដែលអង្គុយនៅជួរខាងមុខ នៅក្នុងនោះមានលោកអភិបាលអន់តូនីផងដែរ។ ពេលដែលចេញផុតពីឡាន លោកអភិបាលដែលមានរបួសស្រាលនៅលើដៃ បានស្រែកសួរ ទៅកាន់បងប្អូនរួមដំណើរ និងសាកសួរសុខទុក្ខគេក្នុងន័យ ប្រសិនបើមានអ្នកណាម្នាក់ប៉ះទង្គិចធ្ងន់ធ្ងរលោកនឹងចាត់ចែងនាំគេទៅសង្គ្រោះនៅមន្ទីរពេទ្យ។ នៅពេលនោះដែរ គេបានទូរស័ព្ទទៅកន្លែងផ្សេងៗដើម្បីជូនដំណឹងនិងឱ្យគេបញ្ជូនមនុស្សមកជួយព្រោះថា រថយន្តត្រូវខូចខាតតែគេនៅតែចង់បន្តដំណើរទៅតាមការគ្រោងទុក។ ក្រោយពីការទាក់ទងមិនយូរប៉ុន្មាន លោកគ្រូមុំបានមកប្តូរយកឡានដែលខូចខាតដើម្បីយកទៅជួសជុល ហើយប្រគល់ឡានថ្មីឱ្យទៅលោកអភិបាលធ្វើដំណើរបន្ត។

គួរពិចារណាទាំងអស់គ្នាថា តើគ្រោះថ្នាក់នៃការធ្វើដំណើរក្នុងនោះ មានបាតុភូតអ្វីកើតឡើងខ្លះ ? ពិតប្រាកដ ណាស់ក្នុងល្បឿនមួយដែលស្រួតដំណើរពីកំពង់ចាមទៅខេត្តមណ្ឌលគិរី មិនអាចបើកបរដូចអ្នកធ្វើដំណើរកំសាន្ត (ដោយល្បឿនយឺត) នោះទេ។ ជាក់ស្តែង ឡានបើកល្បឿនលឿនបង្ហួរផ្សំនឹងបែកកង់ ហើយក្រឡាប់ទៀតនោះគួរតែមានគ្រោះដល់ជីវិតឬមានរបួសធ្ងន់ធ្ងរ ។ ប៉ុន្តែផ្ទុយទៅវិញ គេបែរជាមានរបួសស្រាលៗតែប៉ុណ្ណោះ ។

ឆ្លងតាមជំនឿ និងបទពិសោធន៍របស់យើងជាគ្រិស្តបរិស័ទ យើងមានជំនឿថា: ព្រះវិញ្ញាណគង់នៅជាមួយយើងជានិច្ចក្នុងរាល់អំពើ និងសកម្មភាពរបស់យើង។ ដោយព្រះហឫទ័យសណ្តោសប្រោសប្រណី និងមេត្តាករុណារបស់ព្រះអង្គៗបានជួយថែរក្សាការពារយើងគ្រប់ពេលវេលា ហើយព្រះជាម្ចាស់ក៏បានណែនាំយើងឱ្យ ចេះគោរពច្បាប់ក្នុងសង្គមជាពិសេសច្បាប់ ចរាចរ និង ឱ្យយើងមានការប្រុងប្រយត្ន័ជានិច្ចក្នុងកិច្ចការដែលយើងធ្វើ ។

***បូរ៉ា (កំពង់ចាម)***

---

ស្គាល់កំហុសរបស់ខ្លួន។ ហើយ បើតាមយោបល់ លី គាត់បានពន្យល់ថា: កាលើកលែងទោសជាទង្វើមួយដ៏ពិបាក ប៉ុន្តែមានអត្ថន័យណាស់ចំពោះមនុស្សទូទៅក្នុងសង្គមទាំងមូលត្រង់ថា: គាត់ត្រូវតែនិយាយ និងនៅតែធ្វើអំពើល្អទៅកាន់មនុស្សដែលស្អប់ខ្លួន។ ហើយគាត់សង្ឃឹមថា: អំពើដែលគាត់ធ្វើ នឹងទទួលផលល្អ តបមកវិញគឺទំនាក់ទំនងល្អឡើងវិញ ។ លី បានបញ្ចប់ដោយបន្ថែមថា: ទង្វើខ្លះក៏មិនគួរលើកលែងទោសឱ្យដែរនោះជាអំពើដែលសង្គមស្អប់ខ្ពើមដូចជា អសីលធម៌និងអំពើមួយមិនគប្បីខ្លះទៀតដែលគេមិនទទួលស្គាល់ ។ សរុបសេចក្តីមក ការរិះគិតលើប្រធានបទនេះសមាជិកអង្គប្រជុំមានគំនិតយោបល់ប្រហាក់ប្រហែលគ្នា។ ក្រោយពីនេះ នៅវេលាម៉ោង ៧យប់ ក្រុមបានទៅធ្វើពិធីសម្រុះសម្រួលនៅដន់បូស្កូ-ផ្សារមាន់អាំងទួលគោក ដែលមានលោកបូជាចារ្យប្រាំនាក់ចូលរួម។ ក្រោយពីបានធ្វើពិធីនេះ គេទាំងអស់គ្នាមានទឹកមុខស្រស់ស្រាយដោយបានសារភាពកំហុសរបស់ខ្លួនចំពោះព្រះជាម្ចាស់ និងសុំឱ្យព្រះអង្គលើកលែងទោសឱ្យគេតាមរយៈលោក បូជាចារ្យ។

អស់រយៈពេលពីរថ្ងៃនេះ គេបានទទួលលទ្ធផលយ៉ាងធំធេង ដែលព្រះជាម្ចាស់បានប្រទាន ឱ្យគេយល់កាន់តែច្បាស់ពីការលើកលែងទោសចំពោះអ្នកដទៃ និងធម៌មេត្តាករុណារបស់ព្រះអង្គ ព្រមទាំងជួយឱ្យពួកគេមានភាពស្និទ្ធស្នាល និងចេះយល់ចិត្តថ្លើមគ្នាកាន់តែប្រសើរ ។

***តឿ បូរត្ន័ សារី***

# តើអំពើបាបនៅ...



មនុស្សប្រព្រឹត្តអំពើបាបលើកដំបូង

សេពសន្ថវៈលើអនីតិជន( មនុស្សមានអាយុក្រោម១៨ឆ្នាំដែលច្បាប់មិនទាន់អាចដាក់ទោសទ័ណ្ឌបាន) ការជួញដូរគ្រឿងញៀនដែលត្រូវបានចុះផ្សាយ និងផ្សព្វផ្សាយស្ទើរតែរៀងរាល់ថ្ងៃ តាមរយៈសារពត៌មានវិទ្យុ ឬទូរទស្សន៍ ។

ពតមានបែបនេះ អាចបណ្តាលឱ្យយុវជន-យុវនារីធ្លាក់ទឹកចិត្ត បាត់បង់សេចក្តីសង្ឃឹម និងភាពសប្បាយរីករាយដែលជាចរិតពីធម្មជាតិរបស់គេ នាសម័យសង្គមទំនើបច្ចុប្បន្ននេះ ។ ជួនកាលមានយុវជនខ្លះបានចោទសួរថា: តើហេតុអ្វីបានជាអំពើបាបកំពុងតែរីករាលដាល-បៀតបៀនមកលើប្រជាជនកម្ពុជាបែបនេះ? តើអំពើបាបមានដើមកំណើតចេញមកពីប្រភពណា? ប្រសិនបើ យុវជនមិនបានគិតពិចារណាឱ្យស៊ីជម្រៅទេនោះ ពួកគេប្រាកដជាឆ្លើយថា: ប្រភពនៃអំពើបាបកើតចេញពីប្រទេសជិតខាងកម្ពុជាដែលព្យាយាមបង្កើតភាពច្របូកច្របល់ចលាចលនៅក្នុងប្រទេសដើម្បីឈ្លានពានលេបត្របាក់ទឹកដី ហើយអំពើនេះកាន់តែកើតមានច្រើនឡើងៗ ។ ការគិតបែបនេះប្រហែលជាគេពុំបានស្វែងរកប្រពភពិតនៃអំពើបាបនៅឡើយទេ ។ តាមពិត បាបកម្មនៅកម្ពុជាមិនកើតចេញពីបរទេសទេ ផ្ទុយទៅវិញបាបកម្មនេះកើតចេញមកពីដួងចិត្តរបស់ប្រជាជនកម្ពុជាដែលប្រព្រឹត្តចេញមកពីឆន្ទៈខ្លួនតែម្តង ។



តារាចំរៀងទូច ស៊ុននិច

El Chhinh

ព្រះបន្ទូលរបស់ព្រះជាម្ចាស់ពន្យល់ពីអំពើបាបដើមដំបូងក្នុងអត្ថបទព្រះគម្ពីរកំណើតពិភពលោកត្រង់ជំពូកទី៣នៅក្នុងរឿងនិទាន"មនុស្សប្រុសមនុស្សស្រីដើមដំបូង " ។ ត្រង់នេះ ព្រះជាម្ចាស់បានហាមប្រាមគេទាំងពីរនាក់កុំឱ្យបរិភោគផ្លែឈើមួយដើមដែលដុះនៅចំកណ្តាលសួនឧទ្យាន ។ ក្នុងពេលនោះដែរមានសត្វពស់មួយក្បាលបានមកល្បួងពួកគេដោយពោលថា: " ថ្ងៃណាមួយពេលដែលអ្នកបរិភោគផ្លែឈើនេះ ភ្នែកអ្នកនឹងបានភ្លឺដូចព្រះដែលស្គាល់ល្អ ស្គាល់អាក្រក់ជាមិនខាន" (កំណើតពិភពលោក ៣.៥) ។ ព្រះបន្ទូលនេះបានចង្អុលបង្ហាញពីដើមកំណើតនៃអំពើបាបនៅក្នុងជម្រៅដួងចិត្តមនុស្សយើងដែលមានបំណងលោភលន់ចង់ធ្វើធំដូចព្រះជាម្ចាស់ព្រមទាំងចង់កំណត់ដោយខ្លួនឯងអ្វីជាអំពើល្អ និងអ្វីជាអំពើអាក្រក់ ។ នៅពេល

យើងប្រព្រឹត្តអំពើបាប យើងតែងតែច្រឡំខ្លួនឯងថាៈយើងមានបំណងល្អ ដូចនេះ អំពើខុសឆ្គងបន្តិចបន្តួចរបស់យើង យើងប្រាកដជាគ្មានបញ្ហាអ្វីឡើយ ។

តាមការពិត ដើមកំណើតដ៏ស្លូតស្លើងនៃអំពើបាបមានទិសដៅរបស់វារួចជាស្រេចទៅហើយ ។ អំពើបាប កើតចេញពីសេចក្តីស្រឡាញ់ចំពោះអ្នកដទៃ និងព្រះជាម្ចាស់ដែលផ្ទុយមកវិញ អំពើនេះបានបែរឆ្ពោះតម្រង់ទៅរកភាពអាត្មានិយមគិតតែពីផលប្រយោជន៍ផ្ទាល់ខ្លួន ហើយដែលបដិសេធមិនប្រតិបត្តិសេចក្តីស្រឡាញ់អ្នកដទៃ។ និន្នាការចង់ប្រព្រឹត្តអំពើបាប ជាមេរោគដ៏កាចសាហាវជាងគេនៅក្នុងដួងចិត្តរបស់មនុស្ស ពីព្រោះវានាំយើងឱ្យលង់ខ្លួនចូលស្ថាននរកដោយមិនដឹងខ្លួន ។

សាសនាទាំងអស់លើពិភពលោកបានអប់រំមនុស្សអំពីគុណធម៌ និងសីលធម៌ ពោលគឺ គុណធម៌ និងសីលធម៌មិនមែនជាក្បួនតម្រាដែលយើងអាចបង្កើតឡើងដោយខ្លួនឯងបាននោះទេ។ សីលធម៌ជាមរតកដ៏ថ្លៃថ្នូរបំផុតដែលយើងបានទទួលពីឪពុក ម្តាយ-ជីដូនជីតា និងបុព្វបុរសរបស់យើងតាំងពីបុរាណកាលមកម្លេះ។

ព្រឹត្តិបត្រស្រាវជ្រាវរបស់មជ្ឈមណ្ឌលអភិវឌ្ឍន៍សង្គម លេខ ១០៨ ខែ ធ្នូ ឆ្នាំ២០០៣ បានរកឃើញពីមូលហេតុនៃអំពើបាបនៅក្នុងប្រទេសកម្ពុជាយើងមានពីរយ៉ាងគឺៈទី១" ភាពអវិជ្ជាដែលពោរពេញទៅដោយ ទោសៈ លោភៈ និងមោហៈ"នេះឯង និងទី២"ភាពខ្វះខាតការអប់រំក្នុងគ្រួសារ " ។

បន្ទាប់ពីស្តាប់ដំបូន្មានរបស់សាសនាទាំងនោះអាច ឱ្យយើងដឹងថាៈ ពុំមានពន្លឺបំភ្លឺយើងអំពីរបៀបឈ្នះបាបកម្មដែលកំពុងរាលដាលក្នុងសង្គមខាងលើនេះទេ ។

តាមពិត មានសេចក្តីស្រឡាញ់ដែលកំពុងតែបញ្ចេញឥទ្ធិពលក្នុងសង្គមផងដែរ តែជាធម្មតាគ្មានការសែតឬវិទ្យុ-ទូរទស្សន៍ណាបានរៀបរាប់អំពីរឿងនេះនៅឡើយទេ។ ជាក់ស្តែងក្នុងគ្រួសារខ្មែរ មានម្តាយជាច្រើននាក់កំពុងខិតខំរកស៊ីចិញ្ចឹមកូន ទាំងផ្តល់ភាពកក់ក្តៅដល់កូនតាមរយៈការស្រឡាញ់ បីបាច់ថែរក្សា និងអប់រំកូនយ៉ាងអស់ពីសមត្ថភាព។ ដូចគ្នានេះដែរ ក៏មានឪពុកមួយចំនួនធំបានខិតខំណែនាំ និងអប់រំកូនឱ្យបានដើរក្នុងគន្លងផ្លូវល្អផងដែរ។

ហើយសូម្បីតែព្រឹត្តិការណ៍បាញ់សម្លាប់លោក ជា វិជ្ជា ក៏មានបង្កប់នូវមេរៀនសុក្រិតមួយចំនួនអំពីសេចក្តីស្រឡាញ់សម្រាប់យើងដែរ។ នៅពេលប្រារព្ធពិធីបូជាសពលោក មានកម្មការនីម្នាក់តំណាងឱ្យកម្មករបានថ្លែងសន្ទរកថាដោយបញ្ជាក់ថាៈ"លោកប្រធានបានស្លាប់ទៅមែន ប៉ុន្តែវិរៈភាពរបស់លោក ឧត្តមគតិស្នេហាជាតិរបស់លោក សំឡេងអំពាវនាវរបស់លោក សម្រែកវោហារសព្ទ័ដ៏ត្រលួច និងមានអត្ថន័យរបស់លោកដែលធ្លាប់ឮនៅតាមបណ្តាលរោងចក្រនានានៅពេលកម្មករ-កម្មការនីជួបបញ្ហាទុក្ខលំបាកណែនក្នុងទ្រូងជិតដប់ឆ្នាំកន្លងមកនេះ កំពុងតែឮខ្ទ័រខ្ទារទៅកាន់ពិភពលោកទាំងមូល និងស្ថិតនៅក្នុងក្រអៅបេះដូងរបស់យើងទាំងអស់គ្នាជានិច្ច !

ក្នុងនាមយើងជាគ្រិស្តបរិស័ទដែលបានស្តាប់ឮពាក្យទាំងនេះ យើងនឹកឃើញដល់ព្រះយេស៊ូដែលទ្រង់សព្វព្រះហឫទ័យស្រឡាញ់យើងជាមនុស្សរហូតដល់ព្រះអង្គសោយទីវង្គតលើឈើឆ្កាងដើម្បីផ្តល់ជីវិតថ្មីឱ្យដល់យើង។ តាមគន្លងនេះលោក ជា វិជ្ជា បានជ្រើសរើសផ្លូវមួយដ៏ឧដុង្គឧត្តមដើម្បីជួយសង្គ្រោះប្រជាជនកម្ពុជាឱ្យផុតពីអំពើអយុត្តិធម៌។ ពិតមែនតែម្ចាស់នៃសេចក្តីងងឹត និងសេចក្តីស្លាប់ ស្អប់លោកយ៉ាងណាក៏ដោយ អ្វីដែលម្ចាស់នៃអំពើនេះខ្លាចជាងគេនោះគឺៈពន្លឺនៃសេចក្តីពិត។ ឥឡូវនេះ ពិតជាមានតំណាងកម្មករឡើងជំនួសលោក ជា វិជ្ជា ជា បន្តបន្ទាប់។ ខ្មាំងសត្រូវនៃអំពើយុត្តិធម៌និងសេចក្តីស្រឡាញ់មិនអាចយកឈ្នះលើសច្ចៈធម៌ខាងលើនេះបានឡើយ ប្រសិនបើនៅតែមានអ្នកហ៊ានពុះពារប្រឈមមុខប្រយុទ្ធដើម្បីស្វែងរក និងការពារយុត្តិធម៌ដោយអហិង្សា។

ដូចនេះ អំពើបាបធ្ងន់ធ្ងរជាងគេនៅប្រទេសកម្ពុជាសព្វថ្ងៃ ពុំមែនជាអំពើឃោរឃៅរបស់ជនទាំងនោះទេ ផ្ទុយទៅវិញ គឺភាពអសកម្មរបស់ជនសុចរិត-ទៀងត្រង់ក្នុងការរួបរួមសាមគ្គីគ្នា ស្វែងរកយុត្តិធម៌តាមផ្លូវច្បាប់ដើម្បីបម្រើប្រជាជនយើងក្នុងពេលបច្ចុប្បន្ននេះទៅវិញទេ។

*លោក ឪពុក អាស៊ី*



# ជីវិតអ្នកក្រត្រដរស់

**និពន្ធដោយលោក សួន មករា ជាសិស្សថ្នាក់ទី ១២ នៃវិទ្យាល័យទួលទំពូង ២០០៣-២០០៤**

១ - ខ្សត់ណាស់យ៉ាប់ណាស់ព្រោះតែខ្លួន មិនធូនបន្តការសិក្សា
ត្រូវតែប្រញាប់ចាប់កិច្ចការ រួមផ្សំរជតារៀនបានខ្ពស់ ។
២- ក្រណាស់ព្រួយណាស់គិតរាល់ថ្ងៃ ខិតខំសំចៃច្នៃរកទុក
ស្រោះស្រូបញ៉ាំម្ហូបតែមួយមុខ រស់នៅមិនសុខពិបាកក្រៃ ។
៣- បន្លែប្រហុកញុកចូលមាត់ ព្រោះមកពីហត់ពន់ការងារ
ទឹកភ្នែកលាយបាយរសាយមួយគ្រា ចំជាវេទនាសង្វេកខ្លួន ។
៤- បានលាចខ្វះព្រឹកនឹកមិនឃើញ បងប្រុសស្រីយើងជួយរកគ្នា
ម៉ែឪចាស់ហើយព្រមជរា ត្រូវជួយរកគ្នាទើបរស់បាន ។
៥- ពេលព្រឹកព្រលឹមបេះបន្លែ នៅតាមវាលស្រែឆ្ងាយពីផ្ទះ
ត្រឡប់មកវិញទាន់ថ្ងៃរះ ខិតខំរូតរះកុំយូរការ ។
៦- ពេលបានមកដល់ផ្ទះវិញភ្លាម មិនអង្គុយសៀមត្រូវឆាប់រ៉ា
យកបន្លែទៅលក់ឯផ្សារ បានប្រាក់កាលណាត្រឡប់ថ្កាន ។
៧- មួយថ្ងៃញ៉ាំបាយតែមួយពេល គ្មានមុងកន្ទេលសម្រាកបាន
មើលរូងរាងស្គមពន់ប្រមាណ គ្មានពេលសម្រាន្តស្កប់ស្កល់ឡើយ ។
៨- ខំណាស់រកណាស់ម្ដេចមិនមាន ស៊ូអត់ស៊ូឃ្លាននៅតែក្រ
ឃើញតែគេមានគេស្អាតល្អ រីឯខ្ញុំក្រៗមួយគ្រួ ។
៩- ខំទៅៗមិត្តសំឡាញ់ មិនត្រូវចុះចាញ់ការសិក្សា
ខំរៀនហើយត្រូវធ្វើយ៉ាងណា ឱ្យការសិក្សាបានខ្ពង់ខ្ពស់ ។
១០- ចំណេះវិជ្ជាគឺជាថ្នាំ ចូរមិត្តចងចាំៗឱ្យច្បាស់
បើមានចំណេះការច្រើនណាស់ កំពុងរកម្ចាស់ឱ្យជួយធ្វើ ។
១១- រីឯខ្លួនខ្ញុំក្រពេកក្រៃ រស់នៅរាល់ថ្ងៃគួរអាណិត
ខ្លួនជាអ្នកក្ររស់ខ្សត់មិត្ត នេះជាជីវិតអ្នកក្រខ្ញុំ ។

- ***អ្នកនាំសារ*** ថ្លែងអំណរគុណចំពោះ លោក ***សួន មករា*** ដែលបានផ្ញើអត្ថបទកំណាព្យដ៏មានអត្ថន័យមកចុះផ្សាយលើទំព័រព្រឹត្តិបត្រ*អ្នកនាំសារ*។ *អ្នកនាំសារ* ក៏សូមថ្លែងអំណរគុណចំពោះបងប្អូនទាំងអស់ដែលបានសរសេរអត្ថបទផ្ញើមកកាន់ការិយាល័យអ្នកនាំសារផងដែរ ។ ***អ្នកនាំសារ*** ក៏សូម អភ័យទោសផងដែរ ចំពោះបងប្អូនដែលបានផ្ញើអត្ថបទមកយើងខ្ញុំ ហើយយើងខ្ញុំមិនបានចុះផ្សាយជូនទាន់ពេលវេលា ។
- ***អ្នកនាំសារ*** ក៏សូមអភ័ទោស រាល់កំហុសឆ្គងទាំងឡាយដែលបានកើតមាន (ដោយចេតនា និង អចេតនា ពិសេស អក្ខរាវិរុទ្ធ) ។ យើងខ្ញុំទទួលស្វាគមន៍ជានិច្ច នូវមតិយោបល់ ការរិះគន់កែរតំរូវរបស់បងប្អូន ។ សូមបងប្អូនសរសេរសំបុត្រផ្ញើមក**ការិយាល័យ ព្រឹត្តិបត្រអ្នកនាំសារ :**
**អាសយដ្ឋានផ្ទះ លេខ ៧៨៧ ផ្លូវ ព្រះមុនីវង្ស បឹងត្របែក ភ្នំពេញ**
**ប្រអប់សំបុត្រលេខ ១២៣ ភ្នំពេញ ទូរស័ព្ទ/ទូរសារ (០២៣) ៧២៦ ២៩៧** ឬ
ផ្ញើតាមរយៈ លោកបូជាចារ្យដែលទទួលខុសត្រូវតាមកន្លែងដែលបងប្អូនរស់នៅ ។ ***សូមអរគុណ !***

## សេចក្ដីជូនដំណឹង



ការិយាល័យ ពត មានព្រះសហគមន៍កាតូលិក សូមជំរាបជូនដំណឹងដល់បងប្អូនឱ្យបានជ្រាបថា: យើងខ្ញុំទើបបានផលិតជា ស៊ីឌី និងកាសែតចំរៀង ដែលជាចំរៀងប្រើក្នុងអភិបូជា (វ៉ុលទី១) ។ កាសែត និងស៊ីឌីទាំងនេះនឹងមានដាក់លក់ជូនបងប្អូន ចាប់ពីថ្ងៃផ្សាយដំណឹងនេះតទៅ នៅបណ្ណាគារព្រះវិហារសន្ត យ៉ូសែប (ផ្សារតូច) រឺ ទំនាក់ទំនងមកការិយាល័យយើងខ្ញុំផ្ទះលេខ **៧៨៧ ផ្លូវព្រះមុនីវង្ស ភ្នំពេញ ។ ទូរស័ព្ទ/ទូរសារលេខ (០២៣) ៧២៦ ២៩៧** ។ សូមអរគុណ !

អ្នកនាំសារ

**ក្រុមនិពន្ធ**
គីម រតនា, គីម សំអាត
**រូបភាព :** គុយរិន , Amadeus
**កុំព្យូទ័រ :** លី សុវណ្ណា
ការិល័យផ្សព្វផ្សាយពតិមានព្រះសហគមន៍កាតូលិក
Nº 787, Monivong Blvd,
Phnom Penh-CAMBODIA
Tel/Fax : (855) 23 726 197
E-mail : cscmediacenter@bigfoot.com
អភិបាលគ្រប់គ្រង
លោកអភិបាល អេមីល ដេតម្ប
អគ្គនាយក
លោកបូជាចារ្យ អូមែរ ហ្សិរ៉ាល់ដូ

# វិធីទាំង៧ក្នុងការអធិដ្ឋាន

ដកស្រង់ចេញពីវីដេអូដែលមានឈ្មោះថា seven circle of prayer ដែលចេញផ្សាយដោយ CAHAYA SUARA RESOURCE CENTRE ពីទីក្រុងកូឡាឡាំពួរ ហើយបកប្រែជាភាសាខ្មែរ ដោយបងស្រី សង្វាត នឹង បងស្រី ថារីន ក្រុមគ្រួសារស្រលាញ់ព្រះឈើឆ្កាង។ **តពីលេខមុន**

## ៥-ការប៉ះពាល់




ការអធិដ្ឋានចាប់ផ្តើមឡើងដោយភាពស្ងៀមស្ងាត់និងទីកន្លែងសមស្រប។ ការអធិដ្ឋានធ្វើឱ្យយើងយល់ និងមើលឃើញការតែច្បាស់ឡើងនូវទុក្ខលំបាក។ ការអធិដ្ឋាន ជាការសំដែងចេញការប៉ះពាល់ បបោសអង្អែល ឬការធ្វើទំនាក់ទំនងជាមួយព្រះជា ម្ចាស់ ។

ពេលយើងប៉ះស្ទាប ឬទទួលការប៉ះស្ទាបធ្វើឱ្យដឹង និងទទួលបាននូវការទំនាក់ទំនងជាមួយអ្នកដទៃទាំងនេះគឺ យើងដឹងបានដោយសារស្បែករបសយើង។

ស្បែកធ្វើឱ្យយើងដឹងពេលយើង ប៉ះស្ទាបអង្អែល ។

យើងទទួលបាននូវការប៉ះ ស្ទាបបបោសអង្អែល បានដោយសារស្បែក។ ស្បែកទទួលទំនាក់ទំនងធម្មតានិងការប៉ះ ស្ទាបអង្អែលបាន។ ប៉ុន្តែស្បែកក៏ធ្វើឱ្យយើងដឹង ភាពក្តៅ ត្រជាក់ និងការឈឺចាប់។

ពេលយើងនៅតូច យើងត្រូវការស្ទាប បបោសអង្អែល ថ្នាក់ថ្នមដោយសេចក្តីស្រលាញ់។ សេចក្តីស្រលាញ់ ដែលចេញពីឪពុក-ម្តាយទៅកូន ឬ ពីកូនទៅឪពុកម្តាយវិញ ដោយសារការប៉ះ ពាល់ ស្ទាបបបោសអង្អែល ដោយសេចក្តីស្រលាញ់ និងឆ្លើយតបមកវិញ ដោយសេចក្តីស្រលាញ់ ការប៉ះពាល់ មែនជាកម្មសិទ្ធិរបស់អ្នកណាម្នាក់នោះទេ។

ការប៉ះស្ទាប បបោសអង្អែល ជាអំណោយទានដែលត្រូវចែកចាយឱ្យគ្នាទៅវិញទៅមក។ ការបបោសអង្អែល អាចផ្តល់ឱ្យយើងនូវភាពកក់ក្តៅ ការស្រណុកសុខស្រួល និងភាពធូរស្បើយ។ ការបបោសអង្អែលក៏នាំឱ្យមានឧបសគ្គ និងភាពយល់ច្រឡំផងដែរ។

ពាក្យអង្វរត្អូញត្អែររបស់យើងមិនគ្រប់គ្រាន់ធ្វើឱ្យយើងធូរស្បើយឡើយគឺ យើងត្រូវការ ការប៉ះស្ទាប និងការបបោសអង្អែល ទើបធ្វើឱ្យយើងធូរស្បើយ ។

ដូច្នេះ តើបងប្អូននាំ អំណោយទានរបស់មនុស្សចូលទៅក្នុងការអធិដ្ឋានរបស់ខ្លួនដោយរបៀបណា ?

ពេលបងប្អូនអធិដ្ឋាន សូមចំណាយពេលអង្វរព្រះជាម្ចាស់ ប្រទានពរសំរាប់រាល់ការបបោសអង្អែលទាំងឡាយ។ ពេលបងប្អូនអធិដ្ឋាន គឺបងប្អូនកំពុងធ្វើទំនាក់ទំនងជាមួយព្រះជាម្ចាស់ ព្រះពរនឹងមាននៅលើ ស្បែករបស់បងប្អូនលើដៃរ និងលើរូបកាយទាំងមូល។ ក្រោយមកសូមបងប្អូនលើកយកបងប្អូនណាម្នាក់ដែលត្រូវការ ការបបោសអង្អែលលើកទឹកចិត្ត ចូលក្នុងការអធិដ្ឋានរបស់បងប្អូន។ សូមឱ្យនៅជុំវិញគេពោពេញទៅដោយសេចក្តីស្រលាញ់ ។

-ប្រហែលជាមានបងប្អូនណាម្នាក់ដែលត្រូវការ ការបបោសអង្អែលពីបងប្អូនដោយនិយាយថា " ខ្ញុំ សុំទោស" ។

-ប្រហែលជាមានបងប្អូនណាម្នាក់ដែលត្រូវការការបបោសអង្អែលពីបងប្អូនដោយនិយាយថា "ខ្ញុំលើកលែងទោសឱ្យអ្នក"។

-ប្រហែលជាមានបងប្អូនណាម្នាក់ដែល ត្រូវការការបបោសអង្អែល ពីបងប្អូនដោយនិយាយថា"ខ្ញុំនៅទីនេះហើយ"។ **នៅមានតលេខក្រោយ**